# បទប្បញ្ញត្តិ និងកម្រិតវិន័យ
# ចំពោះបេក្ខជនដែលប្រព្រឹត្តខុសឆ្គង
# នៅពេលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

## I. បទប្បញ្ញត្តិនិងកម្រិតវិន័យចំពោះបេក្ខជនមានបំណងលួចចម្លង

### ១-បទប្បញ្ញត្តិ

ត្រូវបានកំណត់ថាមានបំណងលួចចម្លងនូវសកម្មភាពទាំងឡាយដូចខាងក្រោម ៖

ក-យកជាប់នឹងខ្លួន នូវសៀវភៅ ឯកសារ ឬសំណៅឯកសារ ចូលក្នុងមណ្ឌលប្រឡង

ខ-លាក់ជាប់នឹងខ្លួន នូវសៀវភៅ ឯកសារ ឬសំណៅឯកសារ ឬទូរស័ព្ទដៃ និងឧបករណ៍អេឡិចត្រូនិចគ្រប់ប្រភេទ ។

### ២-កម្រិតវិន័យ

បេក្ខជនណាដែលបានប្រព្រឹត្តសកម្មភាព ដែលមានបំណងលួចចម្លងដូចបានរៀបរាប់ខាងលើ បេក្ខជននោះ ត្រូវប្រគល់រាល់សៀវភៅឯកសារ ឬសំណៅឯកសារឱ្យគណៈមេប្រយោគមុនចូលមណ្ឌលប្រឡងឬបន្ទប់ប្រឡងហើយគណៈមេប្រយោគពុំទទួលខុសត្រូវរាល់ការបាត់បង់ឡើយ។ ក្នុងករណីបេក្ខជនពុំព្រមប្រគល់សៀវភៅឯកសារឬសំណៅឯកសារឱ្យគណៈមេប្រយោគបេក្ខជននោះពុំអនុញ្ញាតឱ្យចូលប្រឡងជាដាច់ខាត ហើយត្រូវបានកំណត់ឱ្យធ្លាក់។

## II. បទប្បញ្ញត្តិ និងកម្រិតវិន័យចំពោះបេក្ខជនលួចចម្លង

### ១-បទប្បញ្ញត្តិ

ត្រូវបានកំណត់ថាជាការលួចចម្លង នូវសកម្មភាពទាំងឡាយ ដូចខាងក្រោម ៖

ក-មានសៀវភៅឯកសារ ឬសំណៅឯកសារសរសេររូបមន្តលើបន្ទាត់ ឬក្រដាសសដោយ ដែកចារ ការចម្លងរូបមន្ត ឬមេរៀននៅលើតុទុកជាមុនការសរសេរលើបាតដៃ លើភ្លៅ លើទ្រនាប់ជើង លើកន្សែងជូតមុខ ។ល។ ក្នុងបន្ទប់ប្រឡង

ខ-ចម្លងសំណៅកិច្ចការពីអ្នកដទៃឬយកកិច្ចការអ្នកដទៃមកដាក់នៅកន្លែងដែលខ្លួនអង្គុយ

គ-អើតមើលសន្លឹកកិច្ចការអ្នកដទៃ

ឃ- ប្រើប្រាស់ទូរស័ព្ទដៃ និងឧបករណ៍អេឡិចត្រូនិចគ្រប់ប្រភេទនៅក្នុងបន្ទប់ប្រឡង

ង-អង្គុយខុសពីលេខតុរបស់ខ្លួនដោយគ្មានការអនុញ្ញាតពីអនុរក្ស ឬរំកិលមកអង្គុយកៀកអ្នកដទៃ

ច-រំកិលតុមកអង្គុយជាប់គ្នា ខុសពីប្លង់កំណត់ដោយគណៈមេប្រយោគ

ឆ-បង្កឱ្យអ្នកដទៃចម្លង

ជ-ប្តូរសន្លឹកកិច្ចការគ្នា ឬប្តូរក្រដាសព្រាងគ្នាឬផ្ទៀងផ្ទាត់ចម្លើយគ្នា ឬចម្លងគ្នាជាក់ស្តែង។

### ២-កម្រិតវិន័យ

បេក្ខជនណា ដែលបានប្រព្រឹត្តសកម្មភាពដូចបានរៀបរាប់ខាងលើ បេក្ខជននោះនឹងបានពិន្ទុសូន្យចំពោះវិញ្ញាសានោះ និងនឹងត្រូវបានបញ្ឈប់មិនឱ្យប្រឡងបន្តទៅទៀតក្នុងសម័យប្រឡងនេះ។

ៗ

## III. **បទប្បញ្ញត្តិនិងគម្រិតវិន័យចំពោះបេក្ខជនដែលធ្វើឱ្យខូចសណ្តាប់ធ្នាប់របៀបរៀបរយនៃការប្រឡង និងប៉ះពាល់កិត្តិយសគណៈមេប្រយោគ**

១-មិនអនុញ្ញាតឱ្យចូលប្រឡងចំពោះបេក្ខជន ដែលមកដល់មណ្ឌលប្រឡង ក្រោយជួងទីពីរដោយចេតនា ឬដោយធ្វេសប្រហែស និងត្រូវបាន**ពិន្ទុសូន្យ**ចំពោះករណីដូចខាងក្រោម៖

ក-សន្លឹកកិច្ចការណា ដែលមានសញ្ញាសម្គាល់អាគតដ្ឋានរបស់ខ្លួន

ខ-ចម្លើយនៃសំណួរណា ដែលមានវិចារដូចគ្នាទាំងស្រុង (Identical scripts / Devoirs Identiques)

គ-ចម្លើយនៃសំណួរណាដែលមានខ្លឹមសារដូចគ្នាទាំងស្រុងទៅនឹងសំណៅវិញ្ញាសា ដែលត្រូវបាននាំចូលក្នុងបន្ទប់ប្រឡង ដោយបេក្ខជន ឬដោយអ្នកដទៃ តាមគ្រប់មធ្យោបាយ ឬក្រោយការធ្វើកោសល្យវិច័យឃើញថាសន្លឹកកិច្ចការនោះមានខ្លឹមសារដូចគ្នាទាំងស្រុងទៅនឹងចម្លើយវិញ្ញាសាដែលមានស្រាប់ ដែលត្រូវបានរៀបចំឡើងដោយខុសច្បាប់។

២-ត្រូវបានកំណត់ឱ្យ**ធ្លាក់** និងផ្អាកមិនឱ្យប្រឡង**មួយឆ្នាំ**បន្ទាប់ចំពោះបេក្ខជនដែលមានសកម្មភាពដូចខាងក្រោម ៖

ក-ដើរចុះឡើងចេញពីកន្លែងអង្គុយ ដោយគ្មានការអនុញ្ញាតពីអនុរក្ស

ខ-ហែកសន្លឹកកិច្ចការ ឬមិនព្រមប្រគល់សន្លឹកកិច្ចការជូនអនុរក្ស

គ-ផ្លាស់កន្លែងអង្គុយ (លុបលេខតុពីកន្លែង ដែលបានកំណត់ ទៅសរសេរលេខតុរបស់ខ្លួននៅកន្លែងផ្សេង)។

ឃ-ឱ្យសន្លឹកកិច្ចការ ឬសំណៅក្រដាសព្រាងរបស់ខ្លួនទៅអ្នកដទៃចម្លង

ង-ឱ្យអ្នកដទៃសរសេរលើសន្លឹកកិច្ចការរបស់ខ្លួន

ច-សរសេរលើសន្លឹកកិច្ចការអ្នកដទៃ

ឆ-បោះប្រធានវិញ្ញាសាចេញក្រៅបន្ទប់ប្រឡង ឬចេញទៅយកសំណៅឯកសារឬចម្លើយពាក់ព័ន្ធនឹងប្រធានវិញ្ញាសាចូលក្នុងបន្ទប់ប្រឡងវិញ ក្នុងពេលធ្វើវិញ្ញាសា

ជ-បង្កជម្លោះនៅក្នុងមណ្ឌលប្រឡង ឬបន្ទប់ប្រឡង ដោយគំរាមកំហែងលើបេក្ខជនដទៃ

ឈ-ដណ្តើមយកសន្លឹកកិច្ចការអ្នកដទៃមកចម្លង

ញ-ហែក ឬលាក់សន្លឹកកិច្ចការអ្នកដទៃ

ដ-យកសន្លឹកកិច្ចការអ្នកដទៃមកធ្វើជាសន្លឹកកិច្ចការរបស់ខ្លួន

ឋ-ធ្វើជាមេខ្លោងប្រមូលលុយ ឬណែនាំឱ្យបេក្ខជនដទៃប្រមូលលុយ ឬយកលុយឱ្យអនុរក្ស។

៣-ត្រូវបានកំណត់ឱ្យ**ធ្លាក់**និងផ្អាកមិនឱ្យប្រឡង**ពីរឆ្នាំ**បន្ទាប់ចំពោះបេក្ខជនដែលមានសកម្មភាពដូចខាងក្រោម ៖

ក-យកអាវុធ ជាតិផ្ទុះ ចូលក្នុងបន្ទប់ប្រឡង

ខ-ឱ្យអ្នកដទៃមកប្រឡងជំនួស

គ-ធ្វើឱ្យខូចសម្ភារៈនៅក្នុងបន្ទប់ប្រឡង និងខូចខាតបន្ទប់ប្រឡងដោយចេតនា

ឃ-មិនអនុវត្តតាមការណែនាំរបស់គណៈមេប្រយោគអ្នកមានសមត្ថកិច្ចក្នុងមណ្ឌលប្រឡង ឬអ្នកមានសមត្ថកិច្ចត្រួតពិនិត្យការប្រឡង។ ក្នុងករណីចាំបាច់បេក្ខជននឹងត្រូវបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ច ដើម្បីដោះស្រាយតាមច្បាប់ជាធរមាន។

៤-ចំពោះបេក្ខជន ដែលបង្កឱ្យខូចរបៀបរៀបរយក្នុងការប្រឡងដូចជាបង្កើតក្លឹបធ្វើចម្លើយនាំសំណៅប្រធានវិញ្ញាសាចេញ នាំសំណៅចម្លើយចូល ឬធ្វើឱ្យប៉ះពាល់ដល់កិត្តិយស ឬរាងកាយរបស់គណៈមេប្រយោគឬអ្នកមានសមត្ថកិច្ចត្រួតពិនិត្យការប្រឡងនឹងត្រូវលុបឈ្មោះចេញពីគ្រឹះស្ថានសិក្សារបស់ខ្លួន រួចបញ្ជូនខ្លួនទៅស្ថាប័នមានសមត្ថកិច្ចដើម្បីដោះស្រាយតាមផ្លូវច្បាប់ជាធរមាន។

**សម្គាល់:** ចំពោះកំហុសក្រៅពីករណី ដែលបានចែងក្នុងកម្រិតវិន័យខាងលើ នឹងត្រូវបានកំណត់ដោយប្រធានគណៈមេប្រយោគមណ្ឌលប្រឡង តាមកំហុសជាក់ស្តែង។

ៗ